**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# ផ្ញើជូន

# អ្នកម្នាង ស៊ីសុវត្ថិ កញ្ញីរ៉េត

*អ្នកម្នាងជាទីរាប់អាន*

ភរិយាខ្ញុំ និងរូបខ្ញុំទើបទទួលដំណឹងដ៏ក្រៀមក្រំ និងដោយក្តីក្តុកក្តួលរំជួលចិត្តឥតឧបមាដោយ **សម្តេច ស៊ីសុវត្ថិ ជីវ័ន្ត មុនីរក្ស** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវជាស្វាមីអ្នកម្នាងបានចូលព្រះទិវង្គត ក្នុងព្រះជន្មាយុ ៨០ ព្រះវស្សា ដោយព្រះរោគាពាធ ។

មរណភាពរបស់សម្តេច គឺជាការបាត់បង់រាជវង្សខ្មែរមួយព្រះអង្គដែលទ្រង់មានឆន្ទៈ មនសិការ ស្នេហាជាតិ សាសនា ព្រះមហាក្សត្ររហូតអស់មួយព្រះជន្ម និងក៏ដូចជាការបាត់បង់ស្វាមី បិតា ប្រកបដោយព្រះព្រហ្មវិហារធម៌ ។

ជាថ្មីម្តងទៀត ខ្ញុំសូមឧទ្ទិសបួងសួងដល់ដួងព្រះវិញ្ញាណក្ខន្ធ **សម្តេច ស៊ីសុវត្ថិ ជីវ័ន្ត មុនីរក្ស** ឆាប់បានកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអ្នកម្នាងទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុតពីភរិយាខ្ញុំ និងរូបខ្ញុំ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៦*

**ហ៊ុន សែន**